# សេចក្តីថ្លែងការណ៍

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ សំដែងការព្រួយបារម្ភចំពោះអ្នកកាន់អំណាចខ្មែរពុំគោរពច្បាប់

**Website: www.hoksavann.org**

ថ្ងៃទី២៨ តុលា ២០០៤

អំពើផ្តាច់ការរបស់អ្នកកាន់អំណាចខ្មែរ បានប្រព្រឹត្តអំពើឧក្រិដ្ឋមក លើប្រជាពលរដ្ឋរបស់ខ្លួន តាំងពីសម័យខ្មែរក្រហមរហូតមកទល់ពេល នេះ ចេះតែរួចពីសំណាញ់ច្បាប់ , ក្នុងពេលបួនដប់ឆ្នាំកន្លងមកនេះទៀត អំពើឧក្រិដ្ឋសម្លាប់អ្នកសារពត៌មាន សម្លាប់សមាជិកគណបក្សប្រឆាំង ការធ្វើគតព្រះសង្ឃសម-ប៊ុនធឿន រហូតដល់សម្លាប់អ្នកចំរៀងដ៏ល្បីឈ្មោះ រហូតមកទល់ពេលនេះ ពុំរកឈ្មោះឃើញឡើយ ។ តើការសម្លាប់ទាំងនោះ ជាការសម្លាប់ដោយមូលហេតុនយោបាយ ដោយការចងគំនុំ ឬដោយអំពើប្លន់ ? ប៉ុន្តែអ្វីមួយបើរដ្ឋាភិបាលចង់ធ្វើគឺធ្វើបានភ្លាម ដូចជាច្បាប់ក្រុមប្រឹក្សារាជសម្បត្តិដើម្បីជ្រើសរើសព្រះមហាក្សត្រ បានចេញជារូបរាងក្នុងរយៈពេលតែមួយអាទិត្យ ។ ច្បាប់កាត់ទោសខ្មែរក្រហមបួនដប់ឆ្នាំមកហើយ ពុំព្រមចេញរួចសោះ ដោយសារតែមានសមាជិកខ្លះនៃរាជរដ្ឋាភិបាលខ្មែរសព្វថ្ងៃជាអតីតខ្មែរក្រហម ហើយបញ្ហាខ្មែរក្រហម នេះ មានការពាក់ព័ន្ធទៅលើប្រទេសចិននិងប្រទេសវៀតណាម ។ ក្នុងពេលថ្មីៗនេះ ប្រធានរដ្ឋសភាខ្មែរបានពោលថា បើទ្រង់មាន៥៥លានដុំ-ល្លារ ទ្រង់នឹងយកទៅជួយអ្នកក្រីក្រខ្មែរ មិនយកទៅចំណាយកាត់ទោសខ្មែរក្រហម ដែលសុទ្ធតែចាស់ៗបួនដប់នាក់នោះទេ ។ សំដីនេះហាក់ដូចជាចង់បង្ហាញឲ្យគេឃើញថា ទ្រង់យកចិត្តទុកដាក់នឹងប្រជាពលរដ្ឋក្រីក្រណាស់ ។ ប៉ុន្តែមានន័យផ្ទុយទៅវិញ គឺទ្រង់យកជើងទៅជាន់លើព្រះកេសព្រះសង្ឃនិងក្បាលប្រជាពលរដ្ឋខ្មែរ ដែលត្រូវខ្មែរក្រហមសម្លាប់រាប់លាននាក់ មិនឲ្យគេរកយុត្តិធម៌ឲ្យអ្នកស្លូតត្រង់ទាំងនោះវិញទេ ។ គឺខ្មោចខ្មែរ២លាននាក់ទៅ៣លាននាក់នោះ មានតម្លៃមិនស្មើ៥៥លានដុល្លារទេ។ ព្រះសង្ឃនិងប្រជាពលរដ្ឋខ្មែរត្រូវសុគតនិងស្លាប់ដូចសត្វតិរច្ឆាន គេចង់បំភ្លេចមិនរកយុត្តិធម៌ទេគឺអំពើយុត្តិធម៌ពុំមានតម្លៃស្មើនឹង៥៥លានដុល្លារឡើយ ។ មួយទៀតគណបក្សទាំងបី ដែលមានតំណាងរាស្ត្រក្នុងរដ្ឋសភា កំពុងតែចាប់ថ្នាក់ប្តឹងផ្តល់គ្នា ។ ការឈ្លោះគ្នារវាងគណបក្សទាំងបី ប្រជាពលរដ្ឋខ្មែរគ្មានខ្វល់អ្វីទេ ប៉ុន្តែប្រជាពលរដ្ឋខ្មែរយកចិត្តទុកដាក់នោះ គឺត្រង់គណបក្សនីមួយៗកេណ្ឌរាស្ត្រឲ្យឈ្លោះជាមួយ គឺឲ្យប្រជាពលរដ្ឋនិងប្រជាពលរដ្ឋឈ្លោះគ្នាដែរ ដែលធ្វើឲ្យប្រជាពលរដ្ឋរងទុក្ខវេទនា ដែលបង្កឡើងពីអ្នកមានអំណាច ដូចបុរាណភាសិតខ្មែរពោលថា ដំរីនិងដំរីជល់គ្នា ស្លាប់ឯស្រមាចនិងសង្ក្អាទៅវិញ ។ ជម្លោះគ្នាក្នុងពេលនេះ ពុំមែនជម្លោះរវាងគណបក្សប្រជាជនកម្ពុជា ដែលជាអតីតគណបក្សកុម្មុយនិស្ត ជាមួយគណបក្សប្រជាធិបតេយ្យទេ គឺជាជម្លោះរវាងគណបក្សហ្វ៊ុនស៊ិនប៉ិចនិងគណបក្សសម-រង្ស៊ី ដែលជាគណបក្សប្រជាធិបតេយ្យសេរីដូចគ្នា ។ គណបក្សប្រជាជនកាលពីមុនមានឥទ្ធិពល បំបែកគណបក្សលោកសឺន-សាន គឺគណបក្សរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែររហូតរលាយទាំងស្រុង ដោយបំបែកផ្ទៃក្នុងនៃគណបក្ស គឺទាញលោកអៀង-មូលី ឲ្យបែកចេញពីលោកតាសឺន-សាន ។ ឥឡូវនេះគណបក្សប្រជាជនកម្ពុជាមើលឃើញថា បើទុកឲ្យគណបក្សហ្វ៊ុនស៊ិនប៉ិចនិងគណបក្សសម-រង្ស៊ីរួមគ្នា ខ្លួនពិបាកទប់ទល់ណាស់ ដូច្នេះត្រូវតែបំបែកគណបក្សទាំងពីរនេះឲ្យបែកគ្នា ដោយរូបមន្តធ្វើរដ្ឋាភិបាលចំរុះតែពីរគណបក្ស គឺគណបក្សប្រជាជនកម្ពុជានិងគណបក្សហ្វ៊ុនស៊ិនប៉ិច ។ ឥឡូវនេះគម្រោងនេះត្រូវបានសំរេច ដោយគណបក្សហ្វ៊ុនស៊ិនប៉ិចនិងគណបក្សសម-រង្ស៊ី ដែលធ្លាប់ធ្វើជាសម្ព័ន្ធភាពជាមួយគ្នាដើម្បីប្រឆាំងគណបក្សប្រជាជន បានត្រូវបែកគ្នា ថែមទាំងចោទគ្នាទៅវិញទៅមកផង ។ ដូច្នេះគណបក្សប្រជាជនកម្ពុជាមានដៃគូ គឺគណបក្សហ្វ៊ុនស៊ិនប៉ិចប្រឆាំងនឹងគណបក្សសម-រង្ស៊ីហើយ ពិសេសគណបក្សប្រជាជនធ្វើជាស្មៀមស្ងាត់មួយពេល ដោយទុកឲ្យគណបក្សហ្វ៊ុនស៊ិនប៉ិចឈ្លោះជាមួយគណបក្សសម-រង្ស៊ី ។ គណបក្សហ្វ៊ុនស៊ិនប៉ិចកំពុងតែភ្លេចខ្លួនសប្បាយ ដោយគណបក្សប្រជាជនលើកដំកើងនិងពោលសរសើរ ។ បើពេលណាគណបក្សសម-រង្ស៊ីមានវាសនាអាក្រក់ត្រូវរលាយ នោះគណបក្សហ្វ៊ុនស៊ិនប៉ិចនឹងមានវាសនាអាក្រក់បន្ទាប់មកទៀត ។ ឧទាហរណ៍នៅប្រទេសលាវ អំឡុងឆ្នាំ១៩៦០ គណបក្សសេរីនិងគណបក្សកុម្មុយនិស្ត រួមគ្នាធ្វើរដ្ឋាភិបាលចំរុះ គឺទ្រង់សុវណ្ណភូមាខាងសេរី និងទ្រង់សុផាវង្សខាងកុម្មុយនិស្ត ដែលមានវៀតណាមនៅពីក្រោយ រួមគ្នាមិនបានយូរប៉ុន្មានឡើយ ដោយគណបក្សកុម្មុយនិស្តដែលនៅក្នុងរដ្ឋាភិបាលចំរុះចេះតែរកលេសចោទសមាជិកនៃគណបក្សសេរី ។ ការចោទនេះមានប្រសិទ្ធិភាព ដោយយូរៗទាញយកម្នាក់ម្តងៗនៃសមាជិកគណបក្សសេរីក្នុងរដ្ឋាភិបាលចំរុះ ទៅកាត់ទោស បាត់ខ្លួន និងបញ្ឈប់ពីការងារ គណបក្សសេរីក៏ត្រូវរលាយ ហើយអំណាចគ្រប់គ្រងប្រទេសធ្លាក់មកលើគណបក្សតែមួយ គឺគណបក្សកុម្មុយនិស្តប៉ាថេតឡាវ បន្ទាប់មកគណបក្សប៉ាថេតឡាវក៏បាត់ឈ្មោះទៅទៀត ។ ចំពោះប្រទេសកម្ពុជាវិញ បើគណបក្សហ្វ៊ុនស៊ិនប៉ិចនិងគណបក្សសម-រង្ស៊ីនៅតែប្តឹងផ្តល់គ្នាទៅវិញទៅមក រហូតចង់ដកអភ័យឯកសិទ្ធិតំណាងរាស្ត្រទៀតនោះ គណបក្សទាំងពីរនេះនឹងត្រូវវិនាសក្នុងទីអវសាន ព្រោះមិនមើលពេលវេលាឈ្លោះគ្នាក្នុងទ្រុងខ្លា ។ តំណាងរាស្ត្រគ្រប់គណបក្សគួរតែមានឧត្តមគតិខ្លួនឯង កុំហែអើទៅតាមប្រធានបក្សដាក់ទិសបើសថាសតាម បើខ្មៅថាខ្មៅតាមឡើយ។ គួរពិចារណាក្នុងពេលថ្មីៗនេះ បន្ទាប់ពីមកពីក្រុងហាណូយប្រទេសវៀតណាម ក្នុងការប្រជុំប្រទេសអាស៊ី-អឺរ៉ុបវិញ ប្រមុខរាជរដ្ឋាភិបាលខ្មែរបានបញ្ជាក់ឲ្យសំរេច នូវច្បាប់ជ្រើសរើសព្រះមហាក្សត្រតែក្នុងរយៈពេលបីបួនថ្ងៃប៉ុណ្ណោះ ហើយបានកេណ្ឌប្រជាពលរដ្ឋ សិស្ស និស្សិតរាប់ម៉ឺននាក់ ទៅទទួលព្រះរាជដំណើរព្រះមហាក្សត្រ ដែលតាមធម្មតានៅប្រទេសសេរី គេមិនកេណ្ឌទេ គឺគេឲ្យទៅដោយស្ម័គ្រចិត្ត តើសកម្មភាពដ៏អធិកអធម្មនេះគេស្រឡាញ់ព្រះមហាក្សត្រពិតប្រាកដ ឬគ្រាន់តែជាកលល្បិចនយោបាយ។៙